# បញ្ញាត្តិ

កែប្រែចុងក្រោយ៖ ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ ២០២៣

**សូមយកចិត្តទុកដាក់ពិនិត្យមើលបញ្ញាត្តិនៃគេហទំព័រនេះ ។**

ក្នុងនាមជាអ្នកប្រើប្រាស់គេហទំព័រនេះ នឹងបង្ហាញថាអ្នកទទួលយកបញ្ញាត្តិទាំងនេះ សូមមេត្តាកុំប្រើប្រាស់គេហទំព័រនេះ ប្រសិនបើអ្នកមិនយល់ព្រមទៅការចងក្រងរបស់គេហទំព័រនេះ ។

បញ្ញត្តិទាំងនេះ អនុវត្តទៅលើការចូលមើល ការប្រើប្រាស់ ទាំងស្រុងឬជាផ្នែកណាមួយនៃគេហទំព័រ ឬកម្មវិធីទូរស័ព្ទរបស់ Coffee Concepts (Cambodia) Limited រួមមាន www.starbucks.com.kh និងគេហទំព័រផ្សេងៗទៀត កម្មវិធីទូរស័ព្ទ ឬសេវាអនឡាញទាំងឡាយណាដែលមានបញ្ញត្តិទាំងនេះភ្ជាប់ជាមួយ ឬក៏បញ្ជាក់ជាឯកសារយោង (រួមគ្នាជា "គេហទំព័រ") ។ បញ្ញត្តិទាំងនេះ មិនបានផ្លាស់ប្តូរប្រការណាមួយនៃលក្ខខណ្ឌទាំងឡាយរបស់កិច្ចព្រមព្រៀងផ្សេងៗទៀត ដែលអ្នកអាចនឹងមានជាមួយ Starbucks ឬក្រុមហ៊ុនចំណុះរបស់ខ្លួន ស្តីអំពីផលិតផល សេវាកម្មនានា ឬអ្វីផ្សេងៗទៀត ។ ប្រសិនបើអ្នកប្រើប្រាស់គេហទំព័រ សម្រាប់បម្រើឲ្យអង្គភាពណាមួយ អ្នកត្រូវតំណាងនិងធានាថា អ្នកត្រូវបានផ្តល់សិទ្ធិក្នុងការទទួលយកបញ្ញត្តិទាំងនេះ ជំនួសឲ្យអង្គភាពនោះ ហើយអង្គភាពនោះយល់ព្រមសងនូវរាល់ការខូចខាតសម្រាប់អ្នក និង Starbucks ចំពោះការបំពានទាំងឡាយណាទៅលើបញ្ញត្តិទាំងនេះ ។ បញ្ញត្តិទាំងនេះ ផ្ទុកនូវប្រយោគបដិសេធ និងការផ្តល់ជូនផ្សេងៗ ដែលកំណត់ព្រំដែននៃកាតព្វកិច្ចផ្លូវច្បាប់របស់យើងខ្ញុំចំពោះអ្នក ។

ក្នុងករណីមានវិវាទ ឬភាពមិនដូចគ្នាណាមួយរវាងបញ្ញត្តិនេះជាមួយនឹងបញ្ញត្តិដទៃទៀត ដែលមាននៅលើគេហទំព័រ យើងនឹងប្រើបញ្ញត្តិនេះមកគ្របដណ្តប់ ។ ប៉ុន្តែប្រសិនបើអ្នកចេញពីគេហទំព័ររបស់យើងទៅកាន់គេហទំព័រភាគីទីបី អ្នកអាចនឹងស្ថិតក្រោមជម្រើសលក្ខខណ្ឌនៃការប្រើប្រាស់ ដែលអាចមានបញ្ជាក់នៅលើគេហទំព័រនោះ ។ ក្នុងករណីបែបនោះ លក្ខខណ្ឌនៃការប្រើប្រាស់របស់គេហទំព័រនោះនឹងគ្របដណ្តប់ទៅលើការប្រើប្រាស់របស់អ្នកវិញ ។

ខណៈពេលដែលយើងព្យាយាមផ្តល់ភាពត្រឹមត្រូវ និងទាន់ពេលវេលាអំពីព័ត៌មាននៃក្រុមហ៊ុន Starbuck Corporation DBA Starbucks Coffee និង/ឬ Coffee Concepts (Cambodia) Limited (រួមគ្នាជា "Starbucks" នៅលើគេហទំព័រ) អ្នកមិនគួរសន្មត់ថា ព័ត៌មានគ្រប់យ៉ាងនៅលើគេហទំព័រនេះសុទ្ធតែថ្មី ឬផ្ទុករាល់ព័ត៌មានដែលមានទាក់ទងអំពី Starbucks ។ ជាពិសេស ប្រសិនបើអ្នកកំពុងធ្វើការសម្រេចលើការវិនិយោគទាក់ទងនឹង Starbucks សូមពិគ្រោះយោបល់ជាមួយប្រភពផ្សេងៗជាមុនសិន រួមទាំងឯកសារ Starbucks ដែលបានដាក់ទៅគណកម្មការមូលបត្រ។

Starbucks រក្សាសិទ្ធិក្នុងការកែប្រែ ឬកែសម្រួលបញ្ញត្តិនេះ ឬគោលការណ៍ណាមួយ ឬក៏ការណែនាំនៃគេហទំព័រ គ្រប់ពេលវេលាដោយសិទ្ធិឯកតោភាគីរបស់ខ្លួន ។ ការកែប្រែ ឬកែសម្រួលណាមួយ នឹងមានប្រសិទ្ធភាពភ្លាម បន្ទាប់ពីធ្វើការបោះផ្សាយនៅលើគេហទំព័រ ហើយអ្នកពុំមានសិទ្ធិក្នុងការទទួលបានការជូនដំណឹងពីការកែប្រែ ឬកែសម្រួលទាំងនោះឡើយ ។ ការបន្តប្រើប្រាស់គេហទំព័រ បញ្ជាក់ថាអ្នកនឹងទទួលយកការកែប្រែ ឬកែសម្រួលទាំងនោះ ដូច្នេះអ្នកគួរតែពិនិត្យបញ្ញត្តិនេះ និងគោលការណ៍ទាំងឡាយឲ្យបានញឹកញាប់ ដើម្បីស្វែងយល់ពីលក្ខខណ្ឌផ្សេងៗ ដែលអនុវត្តលើការប្រើប្រាស់របស់អ្នកនៅលើគេហទំព័ររបស់យើងខ្ញុំ ។ ប្រសិនបើអ្នកមិនយល់ស្របចំពោះបញ្ញត្តិដែលបានកែប្រែ អ្នកត្រូវតែបញ្ឈប់ការប្រើប្រាស់គេហទំព័រទាំងនេះ ។

**សិទ្ធិអ្នកនិពន្ធនិងពាណិជ្ជសញ្ញា៖** លុះត្រាតែមានការកត់សម្គាល់ផ្សេងទៀត ចំណុចសំខាន់ទាំងអស់ និងព័ត៌មាននៅលើគេហទំព័រនេះត្រូវបានការពារថាជាសិទ្ធិអ្នកនិពន្ធ សំលៀកបំពាក់ពាណិជ្ជកម្ម ពាណិជ្ជសញ្ញា និង/ឬ កម្មសិទ្ធិបញ្ញាផ្សេងទៀតដែលជាកម្មសិទ្ធិរបស់ក្រុមហ៊ុន Starbucks និង/ឬ ក្រុមហ៊ុនបុត្តសម្ព័ន្ធរបស់ខ្លួន និងក្រុមហ៊ុនចំណុះ ឬដោយភាគីដទៃទៀតដែលទទួលបានអាជ្ញាប័ណ្ណសំខាន់ៗរបស់ពួកគេពី Starbucks ។
សិទ្ធិទាំងអស់ដែលមិនបានបញ្ជាក់ត្រូវបានរក្សាទុក ។

**ការប្រើប្រាស់ផ្ទាល់ខ្លួន៖** ការប្រើប្រាស់ផ្នែកសំខាន់ៗ ដែលបានរួមបញ្ចូលនៅលើគេហទំព័រនេះគឺ ក្នុងគោលបំណងជាព័ត៌មានតែប៉ុណ្ណោះ ។ អ្នកយល់ព្រមថាអ្នកនឹងមិនចែកចាយ បោះពុម្ពផ្សាយ បញ្ជូន កែប្រែ បង្ហាញ ឬ បង្កើតការងារថតចម្លងពី ឬកេងប្រវ័ញ្ចលើមាតិកានៃគេហទំព័រនេះ ទោះបីក្នុងវិធីណាមួយក៏ដោយ ។ អ្នកយល់ព្រមសងសោហ៊ុយ ការពារ និងមិនបង្កគ្រោះថ្នាក់ដល់ Starbucks សម្រាប់ការប្រើប្រាស់ដោយគ្មានការអនុញ្ញាតណាមួយ ឬទាំងអស់នៅលើគេហទំព័រនេះ ។ អ្នកទទួលស្គាល់ថា ការប្រើប្រាស់មាតិកាដោយគ្មានការអនុញ្ញាត អាចបង្កការខូចខាត ដែលមិនអាចជួសជុលបានដល់ Starbucks ហើយនៅក្នុងករណីដែលការប្រើប្រាស់ដោយគ្មានការអនុញ្ញាត Starbucks ត្រូវបានផ្តល់សិទ្ធិឲ្យក្នុងការចេញសេចក្តីបង្គាប់ បន្ថែមពីលើវិធីផ្សេងទៀតដែលមាននៅក្នុងច្បាប់ឬដោយវិធីសមធម៌។

**មតិយោបល់និងការដាក់ផ្ញើរ៖** អ្នកយល់ព្រមថាអ្នកនឹងទទួលខុសត្រូវមាតិកាដែលខ្លួនអ្នកផ្ទាល់បានដាក់ស្នើ ហើយអ្នកនឹងមិនដាក់សំណើដែលផ្ទុយនឹងច្បាប់ បង្ខូច រំលោភបំពាន ឬអាសអាភាស ។ អ្នកយល់ព្រមថាអ្នកនឹងមិនផ្ញើរជូនអ្វីទៅគេហទំព័រនេះ ដែលនាំអោយមានការរំលោភសិទ្ធិរបស់តតិយជនណាមួយ រួមទាំងការរក្សាសិទ្ធិអ្នកនិពន្ធ ពាណិជ្ជសញ្ញា ឯកជនភាព ឬសិទ្ធិផ្ទាល់ខ្លួន ឬកម្មសិទ្ធិ ។

ក្នុងអំឡុងពេលដែល យើងអរគុណចំពោះការចាប់អារម្មណ៍របស់អ្នកចំពោះ Starbucks យើងមិនចង់ឲ្យ និងមិនអាចទទួលយកគំនិតណាមួយ ដែលអ្នកបានចាត់ទុកជាកម្មសិទ្ធិទាក់ទងនឹង ការរចនាម៉ូត បច្ចេកវិទ្យានៃផលិតផល ឬការស្នើជាយោបល់ផ្សេងទៀតដែលអ្នកអាចនឹងមានដើម្បីអភិវឌ្ឍ ។ ដូច្នេះរាល់ចំណុចសំខាន់ដែលអ្នកដាក់មកគេហទំព័រនេះត្រូវបានចាត់ទុកថាជាការប្រគល់ស្នាដៃនិពន្ធ ការប្រគល់សិទ្ធិដែលមិនមែនជាសិទ្ធិផ្តាច់មុខដោយឥតសំណង និងអាជ្ញាប័ណ្ណសម្រាប់ប្រើប្រាស់ ផលិតឡើងវិញ កែប្រែ បង្ហាញ ផ្ទេរជូន សម្របសម្រួល បោះពុម្ពផ្សាយ បកប្រែ បង្កើតការងារថ្មី និងចែកចាយផ្នែកទាំងនេះទូទាំងសកលលោក នៅក្នុងខ្នាតមធ្យម និងតាមវិធីណាមួយនៃការចែកចាយ បញ្ជូន និងការបង្ហាញអោយគេស្គាល់ ឬ ផ្តើមដាក់ចេញ។ លើសពីនេះទៀត អ្នកធានាថាអ្វីដែលហៅថា "សិទ្ធិសីលធម៌" ត្រូវបានលះបង់ ។

**តំណភ្ជាប់៖** តំណភ្ជាប់មួយចំនួនក្នុងគេហទំព័រនឹងអនុញ្ញាតឲ្យអ្នកតភ្ជាប់ទៅកាន់គេហទំព័រផ្សេងៗទៀតដែលមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់យើងខ្ញុំ។ Starbucks អនុញ្ញាតឲ្យមានតំណភ្ជាប់នេះដើម្បីបង្កភាពងាយស្រួលប៉ុណ្ណោះ ។ បុគ្គលិកលក្ខណៈនៃតំណភ្ជាប់នេះមិនបានបញ្ជាក់ថា Starbucks បានយល់ព្រម ឬទទួលខុសត្រូវលើមាតិកាទាំងឡាយនៃតំណភ្ជាប់របស់គេហទំព័រទាំងនោះឡើយ ។ អ្នកអាចចូលទៅកាន់តំណភ្ជាប់ទាំងនោះដោយទទួលខុសត្រូវលើហានិភ័យដោយខ្លួនឯងផ្ទាល់ ។

**ភាពជាឯកជន ៖** សូមអានគោលការណ៍សិទ្ធិឯកជនឲ្យបានផ្ចិតផ្ចង់ ដើម្បីស្វែងយល់ថាតើ Starbucks ប្រមូល ប្រើប្រាស់ និងចែករំលែកព័ត៌មានឯកជនរបស់អ្នកប្រើប្រាស់ខ្លួន ។

**ការបដិសេធ៖** Starbucks មិនធានាថាមុខងារដែលមាននៅក្នុងគេហទំព័រនេះ មិនត្រូវបានរំខានឬ មានបញ្ហាណាមួយឡើយ ហើយ Starbucks ក៏មិនធានាថាគេហទំព័រនេះ ឬ ម៉ាស៊ីនរក្សាទិន្នន័យ មិនមានមេរោគឬផលប៉ះពាល់ ឬភាពខ្វះចន្លោះផ្សេងៗត្រូវបានជួសជុល ទោះបីជា Starbucks បានដឹងពីបញ្ហាទាំងនេះក៏ដោយ ។ តាមរយៈដែនវិសាលភាពដែលបានអនុញ្ញាតដោយច្បាប់ជាធរមាន Starbucks នឹងមិនទទួលខុសត្រូវចំពោះការបាត់បង់ដោយផ្ទាល់ ដោយប្រយោល ឬមិនចំពោះណាមួយដែលកើតឡើងពីការប្រើប្រាស់មាតិកាដែលមាននៅក្នុងគេហទំព័រនេះ ឬដោយការចូលទៅកាន់ផ្នែកសំខាន់ៗ ដែលមានក្នុងប្រព័ន្ធអ៊ិនធើណេត តាមរយៈតំណភ្ជាប់បណ្តាញពីគេហទំព័រមួយទៅគេហទំព័រមួយ ។ Starbucks មិនទទួលខុសត្រូវចំពោះការក្លែងបន្លំ ការថ្លែងមិនពិត រួមទាំងការស្លាប់ ឬរបួសដោយសារការធ្វេសប្រហែសរបស់បុគ្គលណាមួយឡើយ ។

**អនីតិជនៈ** Starbucks ស្នើសុំឲ្យមាតាបិតាគ្រប់គ្រងកូនៗរបស់ខ្លួន ក្នុងខណៈពេលដែលពួកគេប្រើប្រាស់ប្រព័ន្ធអនឡាញ ។

**យុត្តាធិការៈ** ក្នុងករណីមានវិវាទកើតឡើងពាក់ព័ន្ធនឹងបញ្ញត្តិនេះ គូភាគីយល់ព្រមដោះស្រាយវិវាទដោយសន្តិវិធី ។ ប្រសិនបើវិវាទនេះមិនអាចដោះស្រាយបានក្នុងរយៈពេលពីរខែ (០២) ចាប់ពីកាលបរិច្ឆេទដែលភាគីម្ខាងបានជូនដំណឹងពីវិវាទទៅភាគីម្ខាងទៀត វិវាទនេះនឹងត្រូវដាក់ជូន មជ្ឈមណ្ឌលជាតិអាជ្ញាកណ្តាលពាណិជ្ជកម្ម ក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីធ្វើសេចក្តីសម្រេចជាចុងក្រោយអនុលោមតាមវិធានការរបស់អាជ្ញាកណ្តាល ក្នុងកំឡុងពេលកំពុងអនុវត្ត ហើយដែលវិធាននេះត្រូវចាត់ទុកថាជាឯកសារយោងតាមប្រការនេះ ។ សវនាការ ត្រូវធ្វើឡើងនៅភ្នំពេញ ហើយត្រូវមានការចូលរួមដោយអាជ្ញាកណ្តាលម្នាក់ (០១) ។ ភាសាដែលយកមកប្រើក្នុងសវនាការត្រូវតែជាភាសាអង់គ្លេស ។

សេចក្តីសម្រេចរបស់អាជ្ញាកណ្តាល ជាសេចក្តីសម្រេចចុងក្រោយ និងចងភ្ជាប់កាតព្វកិច្ចរវាងគូភាគី គិតចាប់ពីថ្ងៃដែលចេញសេចក្តីប្រកាស ហើយគូភាគីពុំមានសិទ្ធិតវ៉ាចំពោះច្បាប់ និងពុំមានសិទ្ធិប្តឹងឧទ្ធរណ៍ និង/ឬ តវ៉ាទៅកាន់តុលាការណាមួយឡើយ ។ សេចក្តីសម្រេចពីសវនាការ អាចត្រូវបានស្ថិតក្រោមតុលាការណាមួយដែលមានយុត្តាធិការ ។

Starbucks មិនធានាអះអាងថាផ្នែកផ្សេងៗក្នុងគេហទំព័រនេះត្រឹមត្រូវ ឬអាចប្រើប្រាស់បាននៅទីតាំងផ្សេងទៀតឡើយ ។ ប្រសិនបើលោកអ្នកចូលទីកាន់គេហទំព័រនេះនៅទីតាំងផ្សេងក្រៅពីប្រទេសកម្ពុជា យើងសូមជម្រាបជូនថាគេហទំព័រនេះនឹងមានផ្ទុកនូវផលិតផល និងសេវាកម្មផ្សេងៗទៀតដែលមិនមាន ឬមិនអនុញ្ញាតឲ្យមានក្នុងប្រទេសរបស់លោកអ្នក ។

**ព័ត៌មានអំពីក្រុមហ៊ុន**

Coffee Concepts (Cambodia) Limited

អគារ Morgan Tower លេខ 388 សាលទី7-11 ជាន់ទី12 ផ្លូវសុភមង្គល ភូមិ 14 សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

**ផ្នែកទំនាក់ទំនងអតិថិជន**

លេខទូរស័ព្ទ ០២៣ ៩៨៦ ៥៩១